**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១០០២ សហវ.ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការគ្រប់គ្រងបញ្ញើប្រៃសណីយ៍ បញ្ញើឆាប់រហ័ស និងទំនិញពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១២ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិស័យប្រៃសណីយ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០១ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីបញ្ចូលកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម

ទៅក្នុងឧបសម្ព័ន្ធ១ក នៃកិច្ចព្រមព្រៀងម៉ារ៉ាកេស

- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការដំឡើង សាខាគយនិងរដ្ឋាករចំនួនពីរទៅជានាយកដ្ឋានស្ថិតក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៦៣ សហវ.ប្រក.អគរ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃអង្គភាពថ្នាក់ក្រោមនាយកដ្ឋាន ក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់វិធាននិងនីតិវិធី សម្រាប់ការបំពេញបែបបទគយចំពោះបញ្ញើប្រៃសណីយ៍ បញ្ញើឆាប់រហ័ស និងទំនិញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន ដើម្បីធានាប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្ម ការប្រមូលចំណូលថវិកាជាតិ និងការទប់ស្កាត់បទល្មើសឆ្លងដែន។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះបញ្ញើប្រៃសណីយ៍ បញ្ញើឆាប់រហ័ស និងទំនិញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន ដែលនាំចេញ-នាំចូលព្រះរាជាណាចក្រកម្ពុជា ដោយមិនកំណត់តម្លៃ ទំហំ ទម្ងន់ ប្រភេទប្រតិបត្តិករដឹកជញ្ជូន និងប្រភេទមធ្យោបាយដឹកជញ្ជូន។

**ប្រការ៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម÷

- បញ្ញើប្រៃសណីយ៍ សំដៅដល់កញ្ចប់បញ្ញើដឹកជញ្ជូនឆ្លងកាត់ព្រំដែនដោយប្រតិបត្តិករជាតិ (ប្រៃសណីយ៍កម្ពុជា)
- បញ្ញើឆាប់រហ័ស សំដៅដល់កញ្ចប់បញ្ញើដឹកជញ្ជូនឆ្លងកាត់ព្រំដែនដោយប្រតិបត្តិករបញ្ញើឆាប់រហ័ស
- ទំនិញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន សំដៅដល់ទំនិញត្រូវបានបញ្ជាទិញ-លក់ និងទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក ហើយមានប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ព្រំដែនទៅកាន់អ្នកប្រើប្រាស់ឬអ្នកទិញ (ទោះបីជាមានឬគ្មានលក្ខណៈពាណិជ្ជកម្ម)

- ទម្រង់ CN22/CN23 សំដៅដល់ព័ត៌មានអេឡិចត្រូនិកដែលផ្តល់ដោយប្រៃសណីយ៍កម្ពុជាមុនពេលទំនិញមកដល់ និងត្រូវចាត់ទុកជាប្រតិវេទន៍គយសម្រាប់បញ្ញើប្រៃសណីយ៍ សម្រាប់ការបំពេញបែបបទបញ្ចេញទំនិញពីគយ
- ឯកសារដឹកជញ្ជូន សំដៅដល់ឯកសារក្នុងទម្រង់ក្រដាសឬទម្រង់អេឡិចត្រូនិក ដែលរៀបរាប់លម្អិតអំពីការដឹកជញ្ជូនដែលបានកើតឡើងឬនឹងកើតឡើង។ ឯកសារដឹកជញ្ជូន រួមមាន និវេទនបណ្ណទំនិញ អញ្ញាតបណ្ណ និង/ឬឯកសារផ្សេងទៀត ក្នុងទម្រង់ប្រហាក់ប្រហែល ដែលអាចផ្ទៀងផ្ទាត់បានដោយគយ
- និវេទនបណ្ណទំនិញ (Cargo Manifest) សំដៅដល់បញ្ជីរាយមុខទំនិញដែលដឹកជញ្ជូនតាមជលយាន អាកាសយានឬអយស្ម័យយាន នៃជើងដឹកជញ្ជូនជាក់លាក់
- អញ្ញាតបណ្ណ (Waybill) សំដៅដល់អញ្ញាតបណ្ណមេ និង/ឬអញ្ញាតបណ្ណរង
- អញ្ញាតបណ្ណមេ (Master Bill of Lading/ Master Air Waybill) សំដៅដល់ឯកសារដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន មានបញ្ជាក់ពីព័ត៌មាននៃការដឹកជញ្ជូនទំនិញជាក់លាក់ឬកញ្ចប់ទំនិញរួម ដែលចេញដោយប្រតិបត្តិករដឹកជញ្ជូនទំនិញ ឱ្យទៅប្រតិបត្តិករបញ្ជូនទំនិញឬប្រតិបត្តិករនាវាភារវេទកិច្ច ក្រោយពីព្រមព្រៀងទទួលដឹកជញ្ជូនទំនិញទៅកាន់ទីកន្លែងជាក់លាក់ណាមួយ ស្របតាមលក្ខខណ្ឌនៃការដឹកជញ្ជូន
- អញ្ញាតបណ្ណរង (House Bill of Lading / House Air Waybill) សំដៅដល់ឯកសារដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន មានបញ្ជាក់ពីព័ត៌មាននៃការដឹកជញ្ជូនទំនិញជាក់លាក់ ដែលចេញដោយប្រតិបត្តិករបញ្ជូនទំនិញ ប្រតិបត្តិករបញ្ញើឆាប់រហ័ស ឬប្រតិបត្តិករនាវាភារវេទកិច្ច ក្រោយពីព្រមព្រៀងដឹកជញ្ជូនទំនិញពីអ្នកផ្ញើទំនិញ (Consignor) ទៅឱ្យអ្នកទទួលទំនិញ (Consignee) នៅទីកន្លែងកំណត់ណាមួយ។ អញ្ញាតបណ្ណរងអាចត្រូវបានចេញដោយប្រតិបត្តិករដឹកជញ្ជូនទំនិញ ក្នុងករណីម្ចាស់ទំនិញទទួលសេវាកម្មដឹកជញ្ជូនទំនិញដោយផ្ទាល់ពីប្រតិបត្តិករដឹកជញ្ជូនទំនិញ
- បញ្ញើនាំចូលខុសទិសដៅ សំដៅដល់បញ្ញើប្រៃសណីយ៍ឬបញ្ញើឆាប់រហ័សនាំចូលឬទំនិញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន ដែលអាសយដ្ឋានអ្នកទទួលមិននៅប្រទេសកម្ពុជា ឬពុំមានព័ត៌មានផ្សេងទៀតលើកញ្ចប់បញ្ញើឬលើឯកសារពាក់ព័ន្ធបង្ហាញថា កញ្ចប់បញ្ញើមានគោលដៅមកកម្ពុជា។

**ប្រការ៤.-**

បញ្ញើប្រៃសណីយ៍ បញ្ញើឆាប់រហ័ស និងទំនិញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន ត្រូវបានបែងចែកជាបួនប្រភេទ រួមមាន÷

**ក. បញ្ញើប្រភេទទី១**

បញ្ញើប្រភេទទី១ សំដៅដល់សំបុត្រឬឯកសារគ្មានតម្លៃលក្ខណៈពាណិជ្ជកម្ម និងមិនស្ថិតក្នុងបញ្ជីទំនិញហាមឃាត់ឬទំនិញជាប់កម្រិតកំណត់។ បញ្ញើប្រភេទទី១ ពុំជាប់កាតព្វកិច្ចពន្ធនិងអាករឡើយ។ អញ្ញាតបណ្ណរង

អេឡិចត្រូនិកឬទិន្នន័យអេឡិចត្រូនិកទម្រង់ CN22/CN23 របស់បញ្ញើប្រភេទទី១នេះ អាចចាត់ទុកជាប្រតិវេទន៍គយ និងសម្រាប់ជាមូលដ្ឋានក្នុងការវាយតម្លៃហានិភ័យ។ ក្នុងករណីពុំមានហានិភ័យឬភាពមិនប្រក្រតី បញ្ញើប្រភេទទី១អាចអនុញ្ញាតឱ្យយកចេញពីគយភ្លាម ក្រោយពេលមកដល់។

**ខ. បញ្ញើប្រភេទទី២**

បញ្ញើប្រភេទទី២ សំដៅដល់បញ្ញើដែលមានតម្លៃ (FOB) តិចជាងឬស្មើតម្លៃទំនិញមានតម្លៃទាប (De Minimis) និងមិនស្ថិតក្នុងបញ្ជីទំនិញហាមឃាត់ឬទំនិញជាប់កម្រិតកំណត់។ បញ្ញើប្រភេទទី២ពុំជាប់កាតព្វកិច្ចពន្ធនិងអាករឡើយ។ អញ្ញាតបណ្ណរងអេឡិចត្រូនិក ឬទិន្នន័យអេឡិចត្រូនិកទម្រង់ CN22/CN23 របស់បញ្ញើប្រភេទទី២នេះអាចចាត់ទុកជាប្រតិវេទន៍គយ និងសម្រាប់ជាមូលដ្ឋានក្នុងការវាយតម្លៃហានិភ័យ។ ក្នុងករណីពុំមានហានិភ័យឬភាពមិនប្រក្រតី បញ្ញើប្រភេទទី២អាចអនុញ្ញាតឱ្យយកចេញពីគយភ្លាម ក្រោយពេលមកដល់។

**គ. បញ្ញើប្រភេទទី៣**

បញ្ញើប្រភេទទី៣ សំដៅដល់បញ្ញើដែលមានតម្លៃ (FOB) លើសតម្លៃទំនិញមានតម្លៃទាប (De Minimis) ប៉ុន្តែមានតម្លៃសមមូលមិនលើសពី ១,០០០ (មួយពាន់) ដុល្លារអាមេរិក និងមិនស្ថិតក្នុងបញ្ជីទំនិញហាមឃាត់ឬទំនិញជាប់កម្រិតកំណត់។ បញ្ញើប្រភេទទី៣ជាកម្មវត្ថុនៃការប្រកាសប្រតិវេទន៍គយសង្ខេប និងត្រូវបំពេញកាតព្វកិច្ចពន្ធនិងអាករ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ឃ. បញ្ញើប្រភេទទី៤**

បញ្ញើប្រភេទទី៤ សំដៅដល់បញ្ញើមិនស្ថិតក្នុងបញ្ញើប្រភេទទី១ បញ្ញើប្រភេទទី២ និងបញ្ញើប្រភេទទី៣ខាងលើ។ បញ្ញើប្រភេទទី៤ជាកម្មវត្ថុនៃការប្រកាសប្រតិវេទន៍គយ (ឯកសាររដ្ឋបាលតែមួយ) និងត្រូវបំពេញកាតព្វកិច្ចពន្ធនិងអាករស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៥.-**

ប្រៃសណីយ៍កម្ពុជា ប្រតិបត្តិករបញ្ញើឆាប់រហ័ស និងប្រតិបត្តិករពាក់ព័ន្ធផ្សេងទៀត ត្រូវរៀបចំឬកែសម្រួលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួន ធានាឱ្យមានមុខងារនិងសមត្ថភាពគ្រប់គ្រាន់ ដើម្បីធ្វើសន្ធានកម្មជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្របតាមឧត្តមានុវត្តអន្តរជាតិ។ រាល់ការចំណាយពាក់ព័ន្ធនឹងការធ្វើសន្ធានកម្មប្រព័ន្ធ ជាបន្ទុករបស់ប្រតិបត្តិករសាមី។

**ប្រការ៦.-**

ប្រៃសណីយ៍កម្ពុជាត្រូវផ្តល់ជូនរដ្ឋបាលគយនូវព័ត៌មានបញ្ញើប្រៃសណីយ៍ ក្នុងទម្រង់អេឡិចត្រូនិកស្របតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

ប្រតិបត្តិករបញ្ញើឆាប់រហ័ស និងប្រតិបត្តិករពាក់ព័ន្ធផ្សេងទៀត ត្រូវផ្តល់ជូនរដ្ឋបាលគយ នូវព័ត៌មាននិវេទនបណ្ណទំនិញ អញ្ញាតបណ្ណមេ អញ្ញាតបណ្ណរង និង/ឬទិន្នន័យចាំបាច់ផ្សេងទៀត ក្នុងទម្រង់អេឡិចត្រូនិកនៅមុនពេលបញ្ញើឆាប់រហ័សចេញដំណើរចំពោះការនាំចេញ និងមុនពេលបញ្ញើឆាប់រហ័សមកដល់ចំពោះការនាំចូល តាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាអាចកំណត់នូវលក្ខខណ្ឌផ្សេងទៀត ដើម្បីគ្រប់គ្រង និងសម្រួលពាណិជ្ជកម្មចំពោះបញ្ញើប្រៃសណីយ៍ បញ្ញើឆាប់រហ័ស និងទំនិញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន។

**ប្រការ៧.-**

បញ្ញើប្រៃសណីយ៍ បញ្ញើឆាប់រហ័ស និងទំនិញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន អាចជាកម្មវត្ថុនៃការត្រួតពិនិត្យដោយវិធីសាស្ត្រគ្មានការរំខាន (Non-Intrusive Inspection) ការត្រួតពិនិត្យឯកសារ និង/ឬការត្រួតពិនិត្យរូបវន្ត ដោយផ្អែកលើគោលការណ៍គ្រប់គ្រងហានិភ័យ។

**ប្រការ៨.-**

បញ្ញើនាំចូលខុសទិសដៅឬពុំអាចរកម្ចាស់អ្នកទទួលឃើញ អាចត្រូវបានអនុញ្ញាតឱ្យនាំចេញទៅវិញ ប្រសិនបើពុំមែនជាកម្មវត្ថុនៃការស៊ើបអង្កេតឬហាមឃាត់ និងពុំទាន់បញ្ចប់បែបបទបញ្ចេញទំនិញពីគយនៅឡើយ។ ចំពោះករណីផ្សេងពីនេះ ត្រូវមានការសម្រេចដោយឡែកពីរដ្ឋបាលគយ។

**ប្រការ៩.-**

បែបបទនិងនីតិវិធីលម្អិតនៃការគ្រប់គ្រងការនាំចេញ-នាំចូលបញ្ញើប្រៃសណីយ៍ បញ្ញើឆាប់រហ័ស និងទំនិញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន ត្រូវកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**ប្រការ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រតិបត្តិករពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៤កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី - ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ ១១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ